# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៨៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់វិទ្យាស្ថានសង្គមសាស្ត្រ និងបច្ចេកវិទ្យា

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក. ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និងកីឡា តាមលិខិតលេខ ២៥៨៧ អយក.ឧស ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៧

## សម្រេច

**មាត្រា ១.-**

ទទួលស្គាល់ការបង្កើតគ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា **វិទ្យាស្ថានសង្គមសាស្ត្រ និង បច្ចេកវិទ្យា** ជាភាសាអង់គ្លេស Institute of Social Science and Technology សរសេរកាត់ជាភាសាខ្មែរ វ.ស.ប. និង សរសេរកាត់ ជាភាសាអង់គ្លេស I.S.T ។

**មាត្រា ២.-**

វិទ្យាស្ថានសង្គមសាស្ត្រ និងបច្ចេកវិទ្យា មានទីតាំងស្ថិតនៅ ភូមិវៀនសាំង ឃុំស្វាយរៀង ស្រុកស្វាយរៀង ទីរួមខេត្តស្វាយរៀង និងស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៣.-**

វិទ្យាស្ថានសង្គមសាស្ត្រ និងបច្ចេកវិទ្យា ធ្វើការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង និងបរិញ្ញាបត្រ លើមហា-វិទ្យាល័យបី :

- មហាវិទ្យាល័យ វិទ្យាសាស្ត្រអប់រំ
- មហាវិទ្យាល័យ ព័ត៌មានវិទ្យា
- មហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍

វិទ្យាស្ថាននេះ ត្រូវរៀបចំកម្មវិធីសិក្សាលម្អិត តាមកម្រិត និងមុខជំនាញ ដើម្បីសុំការឯកភាព ពីក្រសួងអប់រំ យុវជន និងកីឡា បន្ទាប់ពីចាប់ដំណើរការបាន ៦ (ប្រាំមួយ) ខែ ។ នៅអនាគតវិទ្យាស្ថាននេះ អាចបើកសាខាមហាវិទ្យាល័យ មុខជំនាញ ប្រភេទបណ្តុះបណ្តាលផ្សេងទៀត ឬ ប្តូរទីតាំងថ្មី ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៤.-**

វិទ្យាស្ថានសង្គមសាស្ត្រ និងបច្ចេកវិទ្យា មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសំរេចលើគោល-នយោបាយ ផែនការអភិវឌ្ឍកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធផ្សេងទៀត ។ តួនាទី ភារកិច្ច និងរចនា-សម្ព័ន្ធចាត់តាំងជាក់ស្តែង នៃវិទ្យាស្ថានសង្គមសាស្ត្រ និងបច្ចេកវិទ្យា ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថាន និងមានការឯកភាព ពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៥.-**

នាយកវិទ្យាស្ថានមានភារកិច្ច :

- ទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងការគ្រប់គ្រងវិទ្យាស្ថាននេះ និងធានាឱ្យមានសុវត្ថិភាព សណ្តាប់ធ្នាប់សង្គម ។
- គោរព និងអនុវត្តតាមការណែនាំ និងបទដ្ឋានដែលពាក់ព័ន្ធនឹងការងារបណ្តុះបណ្តាល របស់ក្រសួងអប់រំ យុវជន និងកីឡា និងច្បាប់របស់រាជរដ្ឋាភិបាល សំដៅធានាគុណភាពអប់រំ ។
- រៀបចំរចនាសម្ព័ន្ធគ្រប់គ្រង ស្របតាមការណែនាំ របស់ក្រសួងអប់រំ យុវជន និងកីឡា ។
- គោរពតាមកិច្ចសន្យាដែលវិទ្យាស្ថានសង្គមសាស្ត្រ និងបច្ចេកវិទ្យា នៅខេត្តស្វាយរៀង បានសន្យាចំពោះក្រសួងអប់រំ យុវជន និងកីឡា ។

- ធ្វើរបាយការណ៍ អំពីការងារបណ្តុះបណ្តាល មកនាយកដ្ឋានឧត្តមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់ ។

**មាត្រា ៦.-**

និស្សិតដែលបានរៀនចប់កម្មវិធីសិក្សា របស់វិទ្យាស្ថានសង្គមសាស្ត្រ និងបច្ចេកវិទ្យា និងទទួលបានជោគជ័យក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងឯកទេស ដែលបានសិក្សា ។ សញ្ញាបត្រនេះផ្តល់ឱ្យដោយវិទ្យាស្ថានសង្គមសាស្ត្រ និងបច្ចេកវិទ្យា ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណី វិទ្យាស្ថានសង្គមសាស្ត្រ និងបច្ចេកវិទ្យា ត្រូវបំពេញ និងអនុវត្តបានតាមគោលការណ៍ និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និង វិទ្យាស្ថានសង្គមសាស្ត្រ និងបច្ចេកវិទ្យា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**<u>កន្លែងទទួល:</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- សាលាខេត្តស្វាយរៀង
- ដូចមាត្រា៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ